**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

JS LAND PLC

**ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី**
លេខៈ២២៣/០១៩/ជមក ជ.អ.ល.

# សេចក្តីជូនដំណឹង

## ស្តីពី ក្រុមហ៊ុន ជេអេស វែនឈ័រ ឯ.ក ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធ នៃក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី វិនិយោគក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលស៊ីអេច ម៉ាយក្រូហ្វាយនែន ម.ក

**ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី ("ជ.អ.ល.")** ជាក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យដំបូងគេក្នុងព្រះរាជាណាចក្រកម្ពុជាដែលបានចុះបញ្ជីភាគហ៊ុនរបស់ខ្លួនជាមួយផ្សារមូលបត្រកម្ពុជា **""ផមក"** មានសេចក្តីសោមនស្សរីករាយសូមជម្រាបជូនវិនិយោគិន និងសាធារណជនទាំងឡាយ មេត្តាជ្រាបថា ក្រុមហ៊ុនបុត្រសម្ព័ន្ធ នៃក្រុមហ៊ុនបុត្រសម្ព័ន្ធ របស់យើងគឺ ក្រុមហ៊ុន ជេអេស វែនឈ័រ ឯ.ក ដែលក្នុងនោះមានក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី ដោយការកាន់កាប់ភាគហ៊ុនកម្មសិទ្ធិចំនួន **៤0%** បានទទួលការយល់ព្រមដោយជោគជ័យពីធនាគារជាតិនៃកម្ពុជា ដើម្បីបន្តនិតិវិធីក្នុងការទិញយកភាគហ៊ុននៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ការវិនិយោគនេះជាយុទ្ធសាស្ត្រសម្របសម្រួលតាមរយៈក្រុមហ៊ុន ជេអេស វែនឈ័រ ឯ.ក របស់យើង ក្នុងនាមក្រុមហ៊ុនបុត្រសម្ព័ន្ធ នៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលមានភាគហ៊ុនកម្មសិទ្ធិចំនួន **៤0%** ដែលបង្ហាញពីការយកចិត្តទុកដាក់របស់ក្រុមហ៊ុនក្នុងការពង្រីកប្រតិបត្តិការអាជីវកម្ម និងការធ្វើពិពិធកម្មផលប័ត្រ ដែលបន្ថែមនូវគុណតម្លៃយ៉ាងប្រពៃសម្រាប់ភាគហ៊ុនិករបស់ក្រុមហ៊ុនយើង។

គិតត្រឹមថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលស៊ីអេច ម៉ាយក្រូហ្វាយនែន ម.ក បានទទួលការអនុញ្ញាតជាផ្លូវការពីធនាគារជាតិនៃកម្ពុជា សម្រាប់ការទទួលស្គាល់សមាជិកក្រុមប្រឹក្សាភិបាលថ្មី; ក្រុមហ៊ុន ជេអេស វែនឈ័រ ឯ.ក កាន់កាប់ភាគហ៊ុនកម្មសិទ្ធិចំនួន **៤0%** ។

លើសពីនេះ ក្រុមហ៊ុន ជេអេស វែនឈ័រ ឯ.ក នឹងត្រូវធ្វើបច្ចុប្បន្នភាពដើមទុនក្នុងលក្ខន្តិកៈ និងឯកសារដែលត្រូវតម្រូវជូនចំពោះធនាគារជាតិនៃកម្ពុជាជាបន្តបន្ទាប់យ៉ាងសកម្មផងដែរ។

រហូតដល់ការបញ្ចប់នីតិវិធីនេះ ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី នឹងត្រូវទទួលបានភាគហ៊ុនកម្មសិទ្ធិចំនួន ១៦% នៅក្នុង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលស៊ីអេច ម៉ាយក្រូហ្វាយនែន ម.ក។ យុទ្ធសាស្ត្រនេះបញ្ជាក់ពីការយកចិត្តទុកដាក់របស់ក្រុមហ៊ុនក្នុងការពង្រីកវត្តមាននៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងការចូលរួមយ៉ាងសកម្មនៅក្នុងការរីកចម្រើនរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលស៊ីអេច ម៉ាយក្រូហ្វាយនែន ម.ក។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ១០ កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣
**ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី JS LAND PLC. KINGDOM OF CAMBODIA

ចុះបញ្ជីក្រោមលេខ
Registration No. 00010332

លេខ B២-១០៧ អគារ The Elysee កោះពេជ្រ វិថីកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#B2-107, The Elysee Diamond Island, Koh Pich Street, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 010 88 66 99
E-mail: info@jslandplc.com, Website: www.jslandplc.com